# ចំណងដៃ ផែនការថ្មី

ដោយ ហួត សេងគៀ

# ភាគទី១

ពេលល្ងាច ជា ពេលដែលមនុស្សរកកន្លែងសម្រាក ក្រោយពីត្រូវប្រឈមមុខនឹងកិច្ចការប្រចាំថ្ងៃរាប់ម៉ោងរួចមក។ ក្នុងផ្ទះតូចមួយដែលស្ថិតក្នុងចំណោមផ្ទះធំៗជាច្រើន មានសម្លេងមនុស្សប្រុសម្នាក់និយាយដោយស្វាហាប់ និង សម្លេងចិញ្ច្រាំសាច់។ ពន្លឺភ្លើងដែលនៅចាំកណ្តាលផ្ទះ បាន បង្ហាញរូបរាងបុរសម្នាក់ដែលកំពុងឈរកាន់កាំបិតហាន់បន្លែមួយដុំធំ។ នៅពីក្រោយខ្នងរបស់គាត់មានកុំព្យូទ័រមួយគ្រឿងដែលកំពុងតែបើកវីដេអូចោល។ តាមពិតមិនមែន បើកចោល ទេ គឺគេកំពុងតែបើកស្តាប់ ដើម្បីកំដរអារម្មណ៍។

"មិនថាអ្វីដែលអ្នកធ្វើតូចប៉ុណ្ណាទេ វាតែងតែមានលទ្ធផលមកឲ្យយើងវិញជានិច្ច។ បើអ្នកមិនធ្វើអ្វីសោះ អ្វីក៏មិនកើតឡើងដែរ"។ សម្លេងចេញពីកុំព្យូទ័រនេះបានហោះចូលទៅក្នុងត្រចៀក ហើយចូលទៅដាស់ខួរក្បាលរបស់គាត់ ឲ្យងក់ក្បាលជា សញ្ញាថា គាត់យល់ពីអ្វីដែលគេនិយាយ។ គាត់យកបន្លែដែលហាន់រួច ដាក់ចូលក្នុងឆ្នាំងដែលកំពុងរំងាស់សាច់យកជាតិ។ គាត់គ្របឆ្នាំងសម្លរួច ក៏ងាកមកអង្គុយ ហើយទាញកុំព្យូទ័រមកចុចដើម្បីតាមដានពត៌មានលើហ្វេសប៊ុក។

គ្រាន់តែបើកភ្លាម គាត់ក៏ឃើញសារពីមិត្តភក្តិម្នាក់។ គាត់ចុចបើកមើលឃើញរូបថតបីសន្លឹក តែមិនទាន់ដឹងថារូបអីទេ ព្រោះអ៊ីនធឺណេតដើរយឺតបន្តិចនៅពេលល្ងាច។ ដំបូងគាត់គិតថា ប្រហែលជារូបអីកំប្លែងៗហើយ ព្រោះមិត្តភក្តិគាត់តែងតែចែកគ្នាសើចដោយរបៀបនេះ។ រូបទីមួយ ក៏លេចឡើង ធ្វើឲ្យគាត់នៅស្ងៀម។ រូបទីពីរ និងទីបី ក៏ចេញមកដំណាលគ្នា។

គាត់ក៏សួរទៅមិត្តភក្តិគាត់ថា "បានរូបនេះមកពីណា?" ។ គាត់ប្រុងនឹងសួរបន្ថែម តែឃើញមិត្តភក្តិរបស់គាត់កំពុងឆ្លើយមកវិញ គាត់ក៏ផ្អាកសរសេរសិន។

"ឃើញមិត្តភក្តិរបស់គេផុស ហើយក៏ save ទុកឲ្យឯងមើលទៅ។ គិតយ៉ាងម៉េចដែរ?" មិត្តភក្តិឆ្លើយ។

គាត់ឆ្លើយតបទៅវិញថា "មានអីត្រូវគិតទេ អរគុណហើយដែលបានផ្ញើឲ្យមើល។ សូមស៊ីបាយបន្តិចសិន ឃ្លានណាស់"។

មិត្តភក្តិរបស់គាត់ក៏សរសេរមកវិញថា "ឥលូវ ឯងដឹងពីមូលហេតុហើយ។ វាល្អម្យ៉ាងដែរ ដែលយើងដឹងចម្លើយ"។ គាត់មើលហើយ មិនបានតបអ្វីទេ ក៏ដាក់ទូរស័ព្ទចុះ រួចដើរទៅចង្ក្រានលើកឆ្នាំងម្ហូបដែលកំពុងតែរំងាស់ យកទៅចាក់ចោល។

គាត់ត្រលប់មកអង្គុយនៅនឹងតុវិញ ហើយចុចមើលទូរស័ព្ទម្តងទៀត។ គាត់សម្លឹងមើលរូបថតដែលមិត្តភក្តិរបស់គាត់ផ្ញើមកម្តងទៀត។ ភ្នែករបស់គាត់ឡើងក្រហម និងរលីងរលោងបន្តិច ប៉ុន្តែគាត់ខាំមាត់ជាប់ ហាក់ដូចជា ស្រែកប្រាប់ឲ្យទឹកភ្នែករបស់គាត់រត់ចូលទៅក្នុងវិញ។ ក្នុងរូបថតនោះមាន មនុស្សស្រីម្នាក់ និង ប្រុសម្នាក់ ស្ថិតក្នុងសម្លៀកបំពាក់រៀបការ។ គាត់មិនស្គាល់ថា ម្នាក់ប្រុសនោះជាអ្នកណាទេ ប៉ុន្តែគាត់ស្គាល់ម្នាក់ស្រីច្បាស់ណាស់។

ទឹកមុខរបស់គាត់ពោរពេញទៅដោយចម្ងល់ តែមិនដឹងជាសួរអ្នកណាបាន។ គាត់ប្រឹងបិទភ្នែកមួយសន្ទុះ មើលទៅដូចជាព្យាយាមលុបសំណួរដែលគាត់មានទាំងប៉ុន្មានចោលឲ្យអស់។ គាត់ក៏នឹកឃើញដល់ពាក្យដែលគាត់ទើបនឹងស្តាប់ក្នុងវីដេអូមុននោះ រួចហើយក៏ញញឹមម្នាក់ឯង។

គាត់គ្រវាសចានបាយដែលដួសហើយមុននោះចេញពីតុ ហើយយកក្រដាសសមួយសន្លឹក មកសរសេរអ្វីម្យ៉ាង។ គាត់ឈ្ងោកមុខសរសេររហូត។ ប្រហែលជា២០នាទីក្រោយមក គាត់ក៏ងើបឡើង ហើយឱនចុះដើម្បីរើសយកអំបែងចានមួយដែលបែកពីចានបាយរបស់គាត់។ គាត់យកវាមកឆូតដៃរបស់គាត់ ហើយដាក់ដៃពីលើក្រដាសមួយផ្ទាំងនោះ។ ឈាមរបស់គាត់តក់មួយដំណក់ហើយមួយដំណក់ទៀត។ គាត់អូសដៃរបស់គាត់យឺតៗ ដើម្បីឲ្យឈាមរបស់គាត់ហូរជាខ្សែនៅលើក្រដាស។

គាត់លើកក្រដាសនោះមកមើលម្តងទៀត រួចបត់ជាបួនជ្រុងទុកក្នុងហោប៉ៅរបស់គាត់។ គាត់ទាញអាវដៃវែងមកពាក់ពីក្រៅ ហើយក៏អូសម៉ូតូជិះចេញទៅក្រៅ។ គ្មានអ្នកណាអាចទាយបានថា តើក្រដាសនោះមានអ្វីសំខាន់នោះទេ។

# ភាគទី២

ព្រះអាទិត្យរះឡើង ថ្ងៃថ្មីមកដល់ ផែនការថ្មីក៏មកដល់ដូចគ្នា។ កំទេចចានកាលពីម្សិលមិញ នៅរាយប៉ាយដូចដើម បានន័យថា គ្មានអ្នករៀបចំ កាលពីយប់មិញ។ បាយដែលជ្រុះទៅ ត្រូវកណ្តុរស៊ីខ្លះ ហើយស្អិតក្រៀមជាប់ដីខ្លះ។ សម្លដែលចាក់ចោល ក៏ជះក្លិនពីធុងសម្រាមមកដែរ ព្រោះគ្មានអ្នកយកទៅចោល។

"អាឡូបង! ស្តាប់លឺច្បាស់អត់?" គាត់កំពុងនិយាយទូរស័ព្ទ។

"អ្នកណាគេហ្នឹង តេរមកទាំងព្រឹកអញ្ចឹង?" ម្ខាងសួរមកវិញ ដោយសម្លេងមិនសូវច្បាស់។

"ខ្ញុំទំនោរ បង! សូមទោសផងបង រំខានបន្តិចហើយ ព្រោះមានការបន្ទាន់" ទំនោរឆ្លើយតបទៅប្រធានផ្នែករបស់ខ្លួន ដោយសម្លេងស្រទន់។

"អូ! ទំនោរ ហើយមានការអីដែរ?" បងប្រធានសួរមកវិញ ព្រោះគាត់ប្រញាប់ដេកបន្ត មុនពេលដល់ម៉ោងទៅធ្វើការ។

"ខ្ញុំចង់សូមច្បាប់មួយអាទិត្យ ព្រោះម្តាយខ្ញុំឈឺធ្ងន់នៅឯស្រុក ហើយខ្ញុំទើបនឹងដំណឹងព្រឹកមិញនេះឯង" ទំនោរប្រាប់ពីហេតុផលរបស់គាត់។

"អុំស្រីឈឺ? ឈប់ទៅៗ ចាំបងដាក់ច្បាប់ឲ្យ។ បើត្រូវការឈប់បន្ថែមទៀត គ្រាន់តែផ្ញើសារមកបងបានហើយ ចាំបងរៀបចំឲ្យ" បងប្រធាននិយាយទៅវិញ។

"អរគុណច្រើន! ខ្ញុំសូមទៅរៀបចំខោអាវហើយ ព្រោះឡានគេមកយកខ្ញុំឥលូវហើយ។ អរគុណម្តងទៀតបង" ទំនោរនិយាយដោយសម្លេងរីករាយ។

"បានហើយអ៊ីចឹង បងទុកហើយ!" គ្រាន់តែចុចបិទភ្លាម គាត់ក៏ដេកបន្តទៀត។

ទំនោរបោះទូរស័ព្ទទៅលើគ្រែ ហើយរៀបចំឥវ៉ាន់មួយចំនួនដាក់ក្នុងកាតាបស្ពាយពីក្រោយធំមួយ រួច ហើយកចេញទៅក្រៅ។

ដោយសារមេឃមិនទាន់ភ្លឺស្រួលបួល ហេតុនេះមិនទាន់មានគេបើកទ្វារផ្ទះអស់ទេ។ ទំនោរចតម៉ូតូនៅក្រោមដើមឈើធំមួយ រួចយកម៉ាស់ និងមួកចេញពីកាតាប ហើយដើរសំដៅទៅផ្ទះមួយដែលមានទ្វារពណ៌ទឹកមាស។ ទំនោរឈរនៅក្បែរនោះ ដោយមិននិយាយអ្វីទាំងអស់។ គាត់មិនងាកចុះងាកឡើង ព្រោះមិនចង់ឲ្យមានអ្នកដទៃសង្ស័យ។ គាត់ធ្វើដូចជាអ្នកដែលទើបនឹងឡើងមកពីខេត្ត ដោយដាក់កាតាបនៅពីខាងមុខកន្លែងឈរ។

ប្រហែលជា២០នាទី សម្លេងបើកទ្វារបានលឺឡើងពីខាងក្រោយខ្នងទំនោរ។ គាត់ដឹងថាម្ចាស់ផ្ទះគេបើកទ្វារផ្ទះ គាត់ក៏ឈរឆ្ងាយបន្តិចពីមុខផ្ទះរបស់គេ។ ទ្វារផ្ទះបើកចំហរ ឡានទំនើបមួយគ្រឿងបានរំកិលខ្លួនចេញពីក្នុងផ្ទះ ដោយមានបុរសម្នាក់ពាក់វ៉ែនតាជាអ្នកបើក។ ក្រោយមកមានសម្លេងមនុស្សស្រីម្នាក់ស្រែកចេញក្នុងផ្ទះ "ម៉ាក់! កូនទៅធ្វើការហើយ"។

មនុស្សស្រីម្នាក់នោះ គឺជាមនុស្សស្រីក្នុងរូបថត ហើយបុរសដែលនៅក្នុងឡាននោះ ជាប្តីរបស់នាង។ ទំនោរមិនហ៊ានសម្លឹងមើលមុខនាងចំទេ ព្រោះខ្លាចប្រទាក់ភ្នែកគ្នា ហើយនាងអាចចំណាំគាត់បាន។ ទំនោរនៅចាំសម្លេង និងកាយវិការរបស់នាងបានទាំងអស់។ អ្វីដែលគាត់មិនអាចចាំបានគឺ តើគាត់ធ្វើអ្វីខុស ទើបបានជានាងកុហកគាត់ទៅរៀបការជាមួយប្រុសថ្មី?

ទំនោរ គិតក្នុងចិត្ត "នីតា! អូនចាំបាច់កុហកបងធ្វើអី? អូនប្រាប់បងថា បែកគ្នាតែមួយពេលទេ ព្រោះអូនមិនសូវសប្បាយចិត្ត។ អូនប្រាប់បងថា អូនមិនមែនមានអ្នកថ្មីទេ។ ឥលូវអូនមិនត្រឹមតែមានអ្នកថ្មី អូនរៀបការជាមួយគ្នាទៀត"។ ទំនោរក្តាប់ដៃជាប់ ប៉ុន្តែប្រឹងធ្វើជាធម្មតា ព្រោះគេមានផែនការផ្សេង។

នីតា ចូលក្នុងឡាន ហើយនិយាយអ្វីជាមួយប្តីរបស់នាង តែទំនោរមិនអាចស្តាប់លឺ។ ពួកគេសើច ហើយប្តីរបស់នាង ក៏ឱនមកថើបថ្ពាល់នាងមួយខ្សឺត មុននឹងបើកចេញទៅ។ ពួកគេ ទើបនឹងរៀបការ ហេតុនេះភាពល្អកល្អើនបែបនេះ ជារឿងធម្មតាទេ។ ទំនោរឃើញរឿងទាំងនេះនៅនឹងភ្នែក ហាក់ដូចជាការគាំទ្រឲ្យទំនោរធ្វើអ្វីដែលគេប៉ងធ្វើកាន់តែរហ័ស។

# ភាគទី៣

នីតា ជាកូនដែលគ្មានឪពុក ហេតុនេះទើបក្រោយពេលរៀបការហើយ ម្ដាយនាង សូមឲ្យប្ដីរបស់នាងមកនៅផ្ទះជាមួយគាត់ គ្រាន់បានជាគ្នា។ ម្ដាយនីតា ជាអ្នកធ្វើការរដ្ឋ ប៉ុន្តែមិនសូវទៅកន្លែងទេ។ ថ្ងៃនេះគាត់នៅផ្ទះ ដើម្បីរៀបចំរបស់របរដែលរញ៉េរញ៉ៃក្រោយពេលការកូនរបស់គាត់។ គាត់សប្បាយចិត្តណាស់ ព្រោះឃើញកូនរកបានមនុស្សដែលអាចទុកចិត្តបាន។ គាត់រៀបចំបណ្ដើរ និយាយម្នាក់ឯងបណ្ដើរ។

គាត់ឈរនៅពីមុខជើងធូប ដែលមានរូបថតបុរសម្នាក់ ហើយនិយាយថា "បង! បើបងបានឃើញប្ដីរបស់អាតា បងក៏សប្បាយចិត្តដូចខ្ញុំដែរ។ កូនគេ មានពូជអំបូរត្រឹមត្រូវ ស្អាតបាត ហើយស្រលាញ់កូនយើងទៀត។ ខ្ញុំអស់ព្រួយហើយពីពេលនេះទៅ"។ គាត់ឈរញញឹមម្នាក់ឯងពីមុខរូបថតនោះ។

គាត់កំពុងស្លុងអារម្មណ៍ជាមួយ ភាពរីករាយ និងកិច្ចសន្ទនាក្នុងក្ដីស្រមៃជាមួយរូបថតប្ដីរបស់គាត់ ក៏ស្រាប់តែមានលឺសម្លេងកណ្ដឹង។ គាត់នឹកស្មានថា គេយកក្រដាសទឹកភ្លើងមកឲ្យ ក៏ដើរចេញទៅបើកទ្វារ។ ទ្វារបើកភ្លាម គាត់សម្លឹងមើលអ្នកដែលកំពុងឈរមុខគាត់ ក៏ប្រែទឹកមុខដូចជាភ្ញាក់ផ្អើល។

"អឺ... ទំនោរ?" គាត់សួរដោយភ្ញាក់ផ្អើល ហើយក៏មិនដឹងថាត្រូវនិយាយអ្វីទៀតដែរ។

"បាទអ៊ំ គឺខ្ញុំ។ នីតានៅផ្ទះទេ?" ទំនោរសួរដោយស្នាមញញឹម។ ដៃរបស់គេនៅកាន់កាតាបដែលយកមកពីផ្ទះដាប់។

"នីតា ទៅធ្វើការបាត់ហើយក្មួយ។ ក្មួយមានការអីដែរ?" ម្ដាយនីតាសួរដោយសង្ស័យ ព្រោះបើតាមអ្វីដែលគាត់ដឹង គឺនីតាបានដាច់ស្រេចគ្នាកាលពីប៉ុន្មានខែមុនទៅហើយ។

"ខ្ញុំដឹងថានីតារៀបការហើយ អ៊ំ។ ពួកខ្ញុំនិយាយគ្នាច្បាស់ហើយ។ នីតា និងខ្ញុំពេលនេះ គ្រាន់តែជាមិត្តភក្តិប៉ុណ្ណោះ។" ទំនោរនិយាយប្រាប់អ៊ំស្រីដើម្បីឲ្យគាត់ទុកចិត្ត ទាំងក្នុងចិត្តដឹងហើយថា អ្វីដែលចេញពីមាត់របស់គាត់ មិនមែនជាការពិតទេ។

"អ៊ំធូរចិត្តបន្តិច។ អ៊ំមិនចង់ឲ្យក្មួយ និងកូនអ៊ំ ក្លាយទៅជាស្អប់គ្នាទេ។" គាត់និយាយដោយយកដៃអង្អែលទ្រូងខ្លួនឯង។

"ខ្ញុំមកចង់លាអ៊ំ ហើយក៏ចង់លានីតាដែរ។ ខ្ញុំក៏បានជួបមនុស្សស្រីម្នាក់ដែរ ហើយឥលូវខ្ញុំត្រូវទៅស្រុកវិញ ដើម្បីហៅឪខ្ញុំមកចូលស្តីដណ្តឹងគេ។ ខ្ញុំខ្លាចមានគេកាត់មុខខ្ញុំបាត់ទៀត។" ទំនោរប្រាប់ពីហេតុផលដែលមកលេង។

"អូ! ល្អមែនក្មួយ។ និស្ស័យមនុស្សមើលមិនឃើញមែន។ កូនអ៊ំក៏មានគូ ក្មួយក៏រកឃើញគូខ្លួនឯង។" អ៊ំស្រីតបទៅវិញ។

ទំនោរ ឱនទៅបើកកាតាបរបស់គេ។ គេខាំមាត់ក្រោយពេលលឺពាក្យអ៊ំស្រីនិយាយពីការរកឃើញគូររបស់កូនស្រីគាត់។

"ខ្ញុំមានរបស់ខ្លះដែលរបស់នីតា ហើយចង់ឲ្យអ៊ំជួយទុកឲ្យនីតាផង។ ខ្ញុំមិនអាចនៅចាំជួបផ្ទាល់ទេ។" ទំនោរហុចប្រអប់មួយធូន់ល្មមទៅកាន់អ៊ំស្រី។

"ចូលសិនមកក្មួយ ផឹកទឹកអីសិន ចាំទៅវិញ" អ៊ំស្រីអែបខ្លួនដើម្បីឲ្យទំនោរអាចចូលទៅក្នុងផ្ទះ។

ទំនោរចូលផុតហើយ អ៊ំស្រីក៏ចាក់ទ្វារវិញ ហើយចាប់ផ្តើមរៀបរាប់ពីរឿងរៀបការរបស់កូនស្រីគាត់។ ទំនោរស្តាប់មិនលឺអ្វីទាំងអស់ ព្រោះពេលនេះភ្នែករបស់គេកំពុងសម្លឹងទៅកាន់រូបថតកូនកំលោះកូនក្រមុំដែលដាក់នៅលើគ្រែ។ ស្នាមញញឹមក្នុងរូបថត ជួយដុតបន្ថែមកំហឹងដែលមានស្រាប់ក្នុងចិត្តរបស់ទំនោរ។ អ៊ំស្រីបានដើរទៅក្រោយរកទឹកមកឲ្យភ្ញៀវដែលមកដោយគ្មានអញ្ជើញនេះ។

ទំនោរក៏លូកដៃចូលក្នុងកាតាបរបស់គេ ហើយដកយកដំបងដែកមួយដើមចេញមក។ គេក៏ដើរលបៗទៅឈរក្បែរច្រកចូលទៅផ្ទះបាយ។ ភ្នែកគេសម្លឹងមើលស្រមោលដែលត្រូវដើរមកកាត់

ជានិច្ច។ ដៃរបស់គេញ័រផង បែកញើសផង ព្រោះគេមិនធ្លាប់ធ្វើបែបនេះពីមុនមកទេ។ គេដឹងច្បាស់ហើយថា គេមិនអាចត្រលប់ក្រោយបានទេ បើធ្វើបែបនេះរួច។

អ៊ំស្រីយកទឹកមួយដប និងកែវជ័រមួយដើរចេញមក។ គាត់ដើរផុតក្លោងទ្វារបន្តិច ទំនោរគាត់យកដំបងវាយក្បាលគាត់ក្រោយមួយទំហឹង។ សម្លេងដំបង ប៉ះនឹងលលាដ៍ក្បាល ធ្វើឲ្យទំនោរភ្ញាក់បន្តិចដែរ។ អ៊ំស្រីដួលទៅនឹងដីភ្លាមៗ ហើយមិនបានប៉ុន្មាន ឈាមក៏ចាប់ផ្ដើមវាតទីលើកម្រាលឥដ្ឋពណ៌ពងមាន់របស់គាត់។ ទំនោរទម្លាក់ដំបងចុះ ហើយអង្គុយក្នុងសភាពតក់ស្លុត។

ក្លិនឈាម ចាប់ផ្ដើមសាយភាយចូលច្រមុះទំនោរ។ គេអង្គុយចុះមើលទៅអ្វីដែលគេបានធ្វើ ហើយក៏ចាប់ផ្ដើមយំ។ "សូមទោសផងអ៊ំ។ សូមទោស ខ្ញុំគ្មានផ្លូវផ្សេងទេ។" ទំនោរនិយាយតិចៗជាមួយរាងកាយដែលដេកស្ដូកស្ដឹងក្នុងថ្លុកឈាម។

# ភាគទី៤

ទ្រនិចនាឡិកាដើរហេូត ទោះបីជាមនុស្សនៅជុំវិញវាមិនធ្វើសកម្មភាពអ្វីក៏ដោយ។ អ៊ំស្រីដេកស្ងៀម នៅលើដី ទំនោរអង្គុយឈ្ងោកមុខក្បែរនោះ។ ត្រឹមតែ៣០នាទីសោះ តែហាក់ដូចជាយូរណាស់សម្រាប់ អ្នកដែលស្ថិតក្នុងស្ថានភាពបែបនេះ។ ទំនោរងើបមុខឡើង ជាមួយនឹងភ្នែកពណ៌ក្រហម ហើយសម្លឹង ទៅលើមុខរបួសដែលគេបានបន្សល់ទុកលើជនរងគ្រោះ។

ទំនោរ ស្គាល់អ៊ំស្រីប្រហែលជាពីរឆ្នាំមកហើយ ព្រោះនីតាធ្លាប់ហៅទំនោរមកលេងផ្ទះ និងហូបបាយជុំ គ្នា។ អ៊ំស្រី មិនធ្លាប់ហាមប្រាម ឬជំទាស់ទំនាក់ទំនងរវាងពួកគេទាំងពីរទេ។ គាត់ក៏មិនដែលនិយាយអ្វី មិនល្អពីទំនោរដែរ ព្រោះគាត់ដឹងថា ទំនោរ ក៏មិនមែនជាមនុស្សទន់ជ្រាយ រង់ចាំស៊ីស្រាប់ៗដែរ។

ទំនោរសម្លឹងទៅរាងកាយអ៊ំស្រី ប៉ុន្តែគេបែរជានឹកឃើញកាលដែលគេមកជួបអ៊ំស្រីដំបូងទៅវិញ។ គេគិតក្នុងចិត្តថា "បើសិនជាគាត់ដឹងថា ការជួបគ្នាជាមួយខ្ញុំ មានលទ្ធផលបែបនេះ តើគា ត់ស្ដាយក្រោយឬទេ?" ។ ទំនោរ មិនដឹងថាអ្វីដែលខ្លួនឯងធ្វើនេះត្រូវ ឬអត់ទេ ប៉ុន្តែគេដឹងថា ផែនការរបស់គេ បានសម្រេចមួយជំហានហើយ។ ជីវិតមនុស្សម្នាក់ ក្លាយជាផ្នែកមួយនៃផែនការរបស់ មនុស្សម្នាក់ទៀត តើនេះឬជាអត្ថន័យរបស់ជីវិត?

ទំនោរក្រោកឡើង យកដំបងដែលប្រើរួចញាត់ចូលក្នុងកាតាបវិញ ហើយបម្រុងនឹងដើរចេញទៅ ប៉ុន្តែ ស្រាប់តែលឺសម្លេងថ្ងូរពីខាងក្រោយខ្នង។ គេដឹងច្បាស់ណាស់ថានេះ មិនមែនខ្មោចលងទេ ប៉ុន្តែវាអា ក្រក់ជាងខ្មោចលងទៅទៀត។ អ៊ំស្រី មិនទាន់ស្លាប់ទេ ហើយគាត់កំពុងតែប្រឹងកម្រើកដៃជើងរបស់ គាត់។

គ្រាប់ញើសធំៗ លេចឡើងលើផ្ទៃមុខរបស់ទំនោរ។ តើគេគួរធ្វើបែបណា? ទំនោរដាក់កាតាបចុះ យ៉ាង ប្រញាប់ប្រញាល់ ហើយដកដំបងដែលគេញាត់ចូលមុននោះ ចេញមកវិញ។ គេកាន់ដំបងយ៉ាងណែន ហើយប្រុងនឹងវាយអ៊ំស្រីម្ដងទៀត ប៉ុន្តែក៏ឈប់វិញ។ គេគិតក្នុងចិត្ត "ចុះបើវាយហើយ គាត់នៅតែមិន ស្លាប់ទៀត តើត្រូវវាយប៉ុន្មានដង?" ពេលនេះ ទំនោរដឹងហើយថា ការសម្លាប់មនុស្សពិបាកប៉ុណ្ណា។

គិតមួយសន្ទុះ ទំនោរ ក៏បានដើរទៅឈរជ្រែងជើងពីលើអ៊ំស្រី ហើយនិយាយថា "អ៊ំ ខ្ញុំមិនបានស្អប់អ៊ំទេ អ្វីដែលខ្ញុំ គឺដើម្បីឲ្យកូនអ៊ំដឹងខ្លួនថាធ្វើខុសប៉ុណ្ណោះ។ សូមទោសផងអ៊ំ។ អ៊ំមិនស្លាប់ម្នាក់ឯងទេ ព្រោះមានមនុស្សច្រើនទៀតដែលទៅកំដរអ៊ំ ខ្ញុំហ៊ានធានា។" ។ លើកនេះ គ្មានការយំស្រែកទៀតទេ ទំនោរនិយាយដោយម៉ឺងម៉ាត់ ហើយក៏យកដំបងដែកនោះមកដាក់លើករបស់អ៊ំស្រី។

ទំនោរប្រើទម្ងន់ជើងទាំងសងខាងសង្កត់ទៅលើដំបងនោះ ហើយចាប់ទាញសក់របស់អ៊ំស្រីមកខាង។ គេខាំមាត់ ហើយទាញកន្ត្រាក់មួយទំហឹង លឺសូរ "ក្រឹក" រួចក៏ព្រលែងដៃទៅវិញ។ អ៊ំស្រីទន់ក ធ្លាក់ទៅលើដីវិញ។ ទំនោរដកដំបងចេញវិញ បង្ហាញឲ្យឃើញស្នាមសង្កត់នៅជាប់ករបស់សាកសព។

ទំនោរ គិតក្នុងចិត្តថា "យ៉ាងហោចណាស់ អ៊ំបានសប្បាយចិត្តមុនពេលស្លាប់ដែរ។ អ៊ំឃើញកូនស្រីរៀបការ នេះជារឿងល្អសម្រាប់មនុស្សចាស់។" ទំនោររៀបចំឧបករណ៍យកជីវិតដាក់ចូលកាតាបវិញ ហើយដើរសំដៅទៅមាត់ទ្វារ។ គេសម្លឹងមើលរូបថតកូនកម្លោះក្រមុំម្តងទៀត ដើម្បីរំលឹកខ្លួនឯងថា គ្រប់យ៉ាងដែលគេធ្វើ គឺមានហេតុផលច្បាស់លាស់។ ទំនោរចេញទៅ ហើយទាញទ្វារបិទដូចធម្មតា។ អ្នកជិតខាងមិនទាន់ក្រោកឡើងគ្រប់គ្នា ហើយអ្នកដែលក្រោក ក៏កំពុងញាប់ដៃញាប់ជើងធ្វើកិច្ចការផ្ទាល់ខ្លួន ហេតុនេះគ្មានអ្នកណាឃើញទំនោរដើរចេញពីផ្ទះនោះទេ។

តាមផ្លូវត្រលប់មកផ្ទះវិញ ទំនោរសួរខ្លួនឯងរហូតថា "តើនេះជាការរស់នៅថ្មីរបស់គេឬ?" ក្រោយពេលនីតាសូមបែកគ្នាជាមួយគេ ទំនោរមិនដឹងថាខ្លួនឯងគួរធ្វើអ្វីទៀតទេ។ នីតា មិនបានប្រាប់ពីមូលហេតុនៃការបែកគ្នា ធ្វើឲ្យទំនោរចំណាយពេលជាច្រើន បង្កើតហេតុផលមកដោយខ្លួនឯង។ មិនថាគេបង្កើតហេតុផលបានល្អប៉ុណ្ណា គេនៅតែមិនអស់ចិត្ត ព្រោះវាមិនមែនចេញពីមាត់របស់នីតា។

ពេលនេះគេដឹងពីមូលហេតុហើយ ទំនោរអាចយល់ពីចិត្តរបស់នីតា។ ប្រហែលជាមិនមែនយល់ចិត្តទេ តែយល់ពីហេតុផលដែលនីតារើសយកអ្នកដទៃ។ ការសម្រេចចិត្តរបស់នីតា ជាការសម្រេចចិត្តដ៏ឆ្លាតមួយ សូម្បីតែទំនោរដែលកំពុងតែខឹងនឹងនីតា ក៏ឯកភាពដែរ។ គិតមកដល់ត្រឹមនេះ ទំនោរក៏ជាន់ហ្វ្រាំងអែមនឹងផ្លូវ។ គេលូកចូលហោប៉ៅ ដកក្រដាសដែលគេសរសេរកាលពីយប់មិញ មកមើល ហើយយកប៊ិចគូសមួយឆ្នូត។ ទំនោរគូសឈ្មោះរបស់អ៊ំស្រីចោល ហើយបត់ទុកវិញ។ តើនៅលើក្រដាសនោះមានឈ្មោះអ្នកណាទៀត ឬទំនោរនៅមានផែនការអ្វីផ្សេងពីការសម្លាប់អ្នកដទៃ?

# ភាគទី ៥

"បងពិស្ដា! ល្ងាចចេញទៅ ចូលទិញអីញ៉ាំផងទៅ ព្រោះម៉ាក់ប្រហែលជាគ្មានពេលធ្វើម្ហូបទេ។" នីតានិយាយទៅកាន់ប្ដីរបស់នាងដែលកំពុងអង្គុយធ្វើការ។ ប្ដីរបស់នាងងើបមើលមុខនាង រួចងក់ក្បាល ហើយក៏បន្តការងារទៀត។ នីតាក៏មិនចង់ឲ្យខាតពេលយូរ ក៏ធ្វើការបង្ហើយ ព្រោះជិតដល់ម៉ោងទៅផ្ទះដែរហើយ។

"ខ្វះតែ១០នាទីទៀតទេ ខ្ញុំបានទៅអង្គុយមើលកុនហើយ" សម្លេងអ្នករួមការងារម្នាក់បានបន្លឺឡើង។ នីតាស្ដាប់លឺហើយ នឹកឃើញ កាលពីនាងមិនទាន់មានគ្រួសារ ក៏ចូលចិត្តទៅដើរលេងក្រោយពេលចេញពីការងារ។ នីតាគិតក្នុងចិត្តថា ជីវិតរបស់នាង ឈានចូលដល់ដំណាក់កាលថ្មីហើយ។ នាងមើលមុខប្ដីរបស់នាង ហើយញញឹមតែម្នាក់ឯង។ នាងឆ្ងល់ខ្លួនឯងថា តើខ្ញុំមានសំណាង ឬគាត់មានសំណាងជាងខ្ញុំដែលបានរៀបការនឹងគ្នាបែបនេះ?

ដប់ប្រាំនាទីក្រោយមក ប្ដីប្រពន្ធថ្មីថ្មោង បណ្ដើរគ្នាចេញពីបន្ទប់ការងារ ដើម្បីទៅរកសុភមង្គលក្នុងផ្ទះ។ ពួកគេដើរបណ្ដើរជជែកគ្នាពីរឿងការងារបណ្ដើរ។ នីតា ស្គាល់ពិស្ដា ប្រហែលជាមួយឆ្នាំ។ ពិស្ដាជាថ្នាក់លើរបស់នាង ហើយក៏ជាអ្នកបង្រៀននាងពីរបៀបទាក់ទងជាមួយភ្ញៀវដែរ។ ភាពស្និទ្ធស្នាលក្នុងការងារ ជួយឲ្យពួកគេបណ្ដុះគ្រាប់ពូជស្នេហា ប៉ុន្តែគ្រាប់ពូជនេះ ក៏បានសម្លាប់ចិត្តរបស់នាងពីទំនោរដែរ។ បើរបស់ថ្មីមិនមក របស់ចាស់ក៏មិនត្រូវគេបោះចោល។

"បង! បត់ចូលហាងគុយទាវក្បែរផ្សារបន្តិចទៅ។ ម៉ាក់ចូលចិត្តទិញកន្លែងហ្នឹង។ គាត់ថាទឹកស៊ុបគេធ្វើឆ្ងាញ់។" នីតាប្រាប់ប្ដីនាងស្របពេលកំពុងជិះតាមផ្លូវ។

"ហើយមានតេរប្រាប់ម៉ាក់ហើយនៅ ថាទិញគុយទាវឲ្យគាត់? ក្រែងលោគាត់ចង់ហូបអីផ្សេង ល្ងាចនេះ។" ប្ដីរបស់នាងសួរបញ្ជាក់ មុននឹងចុចគន្លឹះឡានឲ្យនាងចុះទៅទិញ។

"អូ! មែន តេរទៅម៉ាក់បន្តិចសិន" នីតានិយាយរួច ក៏ទាញទូរស័ព្ទចេញពីកាបូប។

ទូតៗ ទូតៗ ទូតៗ... គ្មានអ្នកលើក។ នាងសាកតេម្តងទៀត ក៏នៅតែគ្មានអ្នកលើក។ នាងក៏ដាក់ទូរស័ព្ទចុះ ហើយនិយាយថា "ម៉ាក់បែបទុកទូរស័ព្ទចោលហើយ អូនចុះទៅទិញ បើគាត់មិនហូប ចាំអូនញ៉ាំក៏បានដែរ។ បងឯងយកអីដែរអត់?"

"អត់ទេ បងចាំទិញបាយឆានៅខាងមុខវិញ។" ប្តីនាងនិយាយបណ្តើរ គ្រវីក្បាលបណ្តើរ។

ម៉ោង៦ជិតកន្លះទើបពួកគេមកដល់ផ្ទះ។ ធ្វើការចេញម៉ោង៥ តែត្រូវប្រយុទ្ធនឹងចរាចរណ៍១ម៉ោងទៀតទើបបានមកផ្ទះសម្រាក។ សំណាងហើយដែលពួកគេជិះក្នុងឡាន មិនបាច់ហិតផ្សែងតាមផ្លូវ។ មកដល់មុខផ្ទះ នីតាចុះទៅគោះទ្វារ។ ដៃរបស់នាងមិនទាន់ទាំងបានរុញផង ទ្វារក៏របើក។ គ្មានដាក់គន្លឹះ? នីតាធ្វើមុខឆ្ងល់ ព្រោះធម្មតាម្តាយរបស់នាង មិនដែលប្រហែសរឿងទ្វារផ្ទះទេ។

នីតារុញទ្វារចូលទៅ អ្វីដែលនាងឃើញមុនគេ គឺរូបរាងម្តាយរបស់នាង ដេកក្រាបនៅនឹងដី ហើយឈាមហូរពេញផ្ទះ។ នាងទម្លាក់ស្បោងគុយទាវដែលនៅជាប់នឹងដីចុះ ហើយរត់ចូលទៅក្នុងផ្ទះ។ ប្តីរបស់នាងឃើញសកម្មភាពនាងដូចជាមិនស្រួល ក៏បើកទ្វារឡានប្រញាប់ប្រញាល់រត់ទៅមើលប្រពន្ធ។

"ម៉ាក់! ម៉ាក់! ភ្ញាក់ឡើងម៉ាក់!" នីតាស្រែកដាស់ម្តាយរបស់នាង។ នាងងាកទៅយំឱបប្តីរបស់នាង ព្រោះនាងដឹងថាម្តាយនាងស្លាប់បាត់ទៅហើយ។ ឈាមដែលហូរស្រស់ៗកាលពីព្រឹកមិញ ពេលនេះស្ងួតជាប់ឥដ្ឋ។ នាងប្រើកម្លាំងអង្រួនម្តាយនាង តែរាងកាយរបស់គាត់រឹងទៅហើយ។

"បង ធ្វើម៉េចទៅ ម៉ាក់ស្លាប់បាត់ហើយ?" នាងសួរប្តីនាងទាំងទឹកភ្នែករហាមពេញមុខ។ សម្លេងញ័ររបស់នាង បានប្រាប់ប្តីនាងថា ពេលនេះនាងមិនអាចធ្វើអ្វីបានទេ។

"ចាំបងតេរហៅគេមកជួយសិន" ប្តីរបស់នាងព្យាយាមរម្ងាប់អារម្មណ៍ប្រពន្ធដែលកំពុងតែក្តុកក្តួល។ ពិស្តា យកទូរស័ព្ទតេរហៅប៉ូលីសដើម្បីមកធ្វើការត្រួតពិនិត្យ រួចហើយក៏ត្រលប់មកឱបប្រពន្ធវិញ។ គេកំពុងតែឆ្ងល់ថា តើអ្នកណាអីក៏ព្រៃផ្សៃម្លេះ ធ្វើបែបនេះដាក់មនុស្សចាស់។

ប្តីរបស់នាង ក៏តេរហៅបងប្អូនមកជុំគ្នា ដើម្បីចាត់ចែងបុណ្យសព។ នីតាធ្វើអ្វីមិនកើតទេពេលនេះ ក្រៅពីអង្គុយមើលម្តាយនាង។ នាងរស់នៅជាមួយម្តាយនាងតែពីរនាក់យូរហើយ ឥលូវស្រាប់តែគាត់ទៅបាត់ដោយមិនបានប្រាប់អ្វីនាងមួយម៉ាត់។ នាងកាន់ដៃរបស់ម្តាយជាប់ ហើយទឹកភ្នែកដែលនៅសល់ក្នុងភ្នែកនាងទាំងប៉ុន្មាន ហូរបន្ត ជាការលាគ្នា។

នីតា ទើបតែឃើញម្ដាយនាងសើចបិទមាត់មិនជិត ពេលនាងរៀបការកាលពីម្សិលមិញ ។ នាងនឹកស្មានថា ម្ដាយនាងអាចនឹងរីករាយជាមួយគ្រួសារថ្មីរបស់នាង និងអាចនៅចាំពរចៅទៀត។ នាងមានពាក្យជាច្រើនដែលមិនទាន់បាននិយាយជាមួយម្ដាយ ប៉ុន្តែពេលនេះ ហួសពេលហើយ។ នាងសម្លឹងមើលទៅរូបថតឪពុករបស់នាង ហើយសួរក្នុងចិត្តថា "ហេតុអីប៉ាមិនជួយម៉ាក់ផង? ប៉ាចង់យកម៉ាក់ទៅជាមួយមែនទេ បានជាឲ្យមានរឿងនេះកើតឡើង?" នាងងាកមើលជុំវិញខ្លួន ដើម្បីរកអ្វីមកបន្ទោស ព្រោះនាងមិនអាចធ្វើអ្វីបានទៀតទេ។ ចាប់ពីថ្ងៃនេះទៅ នាងក្លាយជាកូនកំព្រាហើយ។

សាច់ញាតិជិតឆ្ងាយ បានមកបណ្ដើរៗ ដើម្បីរៀបចំពិធីបុណ្យសព។ អ្នកដែលមកដល់មុន យំស្រែកព្រោះវាកើតឡើងលឿនពេក។ អ្នកដែលមិនយំទន់ខ្លួន រត់ការរៀបចំបុណ្យសព ដើម្បីឲ្យព្រលឹងរបស់អ្នកស្លាប់ទៅបានសុខ។ ប៉ូលីស កំពុងធ្វើការរបស់ប៉ូលីស ហើយពួកគាត់ក៏បានចូលរួមសោកស្ដាយចំពោះការបាត់បង់របស់គ្រួសារ។ ប៉ូលីស ដើរសួរអ្នកជិតខាង ដោយសង្ឃឹមថាបានតម្រុយខ្លះ ប៉ុន្តែគ្មានអ្នកណាដឹងថា គាត់ស្លាប់ពីពេលណាទេ។ ប៉ូលីសដើរមើលជុំវិញនោះ ក្រែងអាចប្រទះនឹងអាវុធដែលឃាតករប្រើ ឬភស្តុតាងអ្វីថ្មី។

ប៉ូលីសដុះពោះម្នាក់និយាយថា "ឯងជឿទៅ រឿងបែបនេះ ឈាមស្រែកស្បែកហៅទេ។ មិនយូរទេ យើងនឹងចាប់អាអ្នកសម្លាប់អ៊ំស្រីហ្នឹងបានមិនខាន"។ ប៉ូលីសផ្សេងទៀត ទោះបីជាមិនយល់ស្របក៏ចេះងក់ក្បាលទៅ ព្រោះមេហាមាត់ទៅហើយ។ តើឈាមអាចស្រែកបានទៀតទេ បើវាកកអស់ទៅហើយ? តើវាអាចស្រែកបានដោយរបៀបណា បើគ្រប់យ៉ាងស្ថិតក្នុងផែនការរបស់គេហ្នឹង?

# ភាគទី ៦

ម្ខាងកើតទុក្ខ ព្រោះបាត់បង់មនុស្សជាទីស្រលាញ់ ម្ខាងទៀតនៅមិនសុខ ព្រោះមិនដឹងថាអ្វីដែលខ្លួនបានធ្វើ ជារឿងត្រូវ ឬខុស។ ទំនោរឈរក្នុងបន្ទប់ទឹកម្នាក់ឯង ច្របូកច្របល់ក្នុងគំនិត លាយឡំនឹងរូបភាពដែលគួរឲ្យអានិតរបស់អ៊ំស្រី។ ភ្នែកសម្លឹងទៅក្នុងកញ្ចក់ ឃើញមុខមាត់របស់ខ្លួនឯងដែលជោគជាំទៅដោយដំណក់ទឹក ធ្វើឲ្យគេគិតថាខ្លួនឯងហាក់ដូចជាមនុស្សផ្សេងម្នាក់ទៀត។ ម្នាក់ជាអ្នកធ្វើ ម្នាក់ទៀតជាអ្នកស្តាយក្រោយ។

ទំនោរ នឹកឃើញពេលដំបូងដែលជួបមុខអ៊ំស្រី។ ពេលនោះ គេជូននីតាទៅផ្ទះ ហើយចំពេលដែលអ៊ំស្រីកំពុងឈរចងស្បោងសម្រាមនៅមុខផ្ទះ។ ពេលឃើញភ្លាម ទំនោរគិតក្នុងចិត្តថាប្រាកដជាមានរឿងមិនខាន។ បើសិនជាយ៉ាប់ខ្លាំង អាចនឹងត្រូវឈប់ទាក់ទងគ្នាទៀតផង ប៉ុន្តែក្រោយពេលគេលើកដៃសំពះជម្រាបសួរអ៊ំស្រីរួច គេក៏បានទទួលស្នាមញញឹមយ៉ាងរាក់ទាក់ពីគាត់វិញ។ អ៊ំស្រីក៏ហៅគេឲ្យចូលផ្ទះអង្គុយនិយាយគ្នាលេងសិន។ គេសម្លឹងមុខនីតា ឃើញនាងញញឹមងក់ក្បាល ទើបគេដឹងថា គ្មានរឿងអីកើតឡើងទេ។

"អ៊ំមិនឃាត់ឃាំងអ្វីទេ តែធ្វើឲ្យអីចេះគិតផង ហើយកុំធ្វើបាបកូនអ៊ំ ព្រោះគ្នានៅក្មេងណាស់" អ៊ំស្រីនិយាយពេលទំនោរកំពុងអូសម៉ូតូចេញពីក្នុងផ្ទះវិញ។ ទំនោរមិនតបអ្វីច្រើន ក្រៅពីសើច ហើយនិយាយថា "បាទអ៊ំ"។

ការចងចាំពីអតីតកាល ត្រូវបានរំខានដោយសម្លេងទូរស័ព្ទរបស់ទំនោរ។ គេជូតមុខ ហើយរលាស់ទឹកចេញពីដៃរបស់គេ រួចដើរចេញពីបន្ទប់ទឹកទៅលើកទូរស័ព្ទ។ ឈ្មោះនៅលើអេក្រង់ទូរស័ព្ទ គឺមករា ដែលជាមិត្តភក្តិធ្លាប់រៀនជាមួយគ្នា ហើយក៏ជាអ្នកដែលផ្ញើរូបថតរៀបការរបស់នីតាឲ្យគេមើលដែរ។ នៅពេលមានរឿងអីកើតឡើងទាក់ទងនឹងនីតា មករាតែងតែប្រាប់មិត្តសម្លាញ់របស់គេជានិច្ច ព្រោះគេដឹងច្បាស់ថា ក្នុងចិត្តទំនោរ នៅតែស្រលាញ់នីតាដូចដើម។ ចិត្តដែលមករាដឹង អាចនឹងមានការប្រែប្រួលបន្តិចហើយនៅពេលនេះ។

ទំនោរលើកទូរស័ព្ទហើយនិយាយ "អាឡូ មានការអី?"

"អេ ដឹងអត់? អ៊ំម៉ាក់នីតាស្លាប់បាត់ហើយ មានគេចូលសម្លាប់គាត់ដល់ក្នុងផ្ទះ ពេលនីតាអត់នៅ"

ទំនោរ ស្ងាត់មួយសន្ទុះ ព្រោះរៀបពាក្យនិយាយមិនត្រូវ រួចសួរថា"ហើយម៉េចបានជាឯងដឹង?"

"ឃើញមិត្តភក្តិនីតាផុសនៅលើហ្វេសប៊ុក ថាទៅចូលរួមពិធីបុណ្យសពនៅផ្ទះនីតា"

"ច្បាស់អត់ថាជាផ្ទះនីតា" ទំនោរសួរបញ្ជាក់ ដោយព្យាយាមធ្វើជាភ្ញាក់ផ្អើលនឹងពត៌មាននេះ។

"ច្បាស់ណាស់ ស្មានតែឯងមិនចាំមុខផ្ទះនីតាអី?" មករាតប រួចបន្ត "ទំនេរអត់? បើទំនេររៀបចំខ្លួនទៅចូលបុណ្យគាត់បន្តិចទៅ"

ទំនោរស្ទាក់ស្ទើរមិនដឹងថាគួរទៅឬមិនគួរ "ដូចមិនសមទេដឹង គេអត់មានហៅយើងផង ហើយខ្ញុំជាមួយនីតា បានដាច់ស្រេចគ្នាហើយ"។

មករា ឆ្លើយវិញថា "បុណ្យខ្មោច ចាំគេហៅដែរ? ផ្អាកគិតរឿងបែកគ្នាសិនទៅ ឯងក៏ស្គាល់អ៊ំម៉ាក់នីតាដែរ ហើយបើតាមខ្ញុំចាំ គាត់ដូចជាមិនអាក្រក់ជាមួយឯងទេ។ រៀបខ្លួនឲ្យហើយ បន្តិចទៀតខ្ញុំទៅយក។ យើងទៅលាគាត់ជាលើកចុងក្រោយ។" មករាចុចបិទ ព្រោះមិនចង់ស្តាប់ហេតុផល drama របស់ទំនោរ។

ទំនោរហាក់ដូចជាភ័យ ព្រោះបើសិនជាទៅហើយ មានគេសង្ស័យ គេច្បាស់ជាត្រូវគេចាប់នៅកន្លែងមិនខាន តែបើមិនទៅ ក៏អាចធ្វើឲ្យគេសង្ស័យដែរ។ គិតរួចហើយ គេដើរទៅរកអាវសខោខ្មៅមកពាក់ដើម្បីចូលរួមពិធីបុណ្យសព ដែលកើតឡើងដោយសារស្នាដៃរបស់គេ។

---

ពេលព្រឹក នៅផ្ទះនីតា

ពិធីបុណ្យសពបានប្រារព្ធធ្វើឡើងតាមប្រពៃណីជនជាតិចិន។ ញាតិមិត្តចាប់ផ្តើមមកចូលរួមជាបន្តបន្ទាប់ ហើយចូលគោរពវិញ្ញានក្ខន្ធសព ទៅតាមលំដាប់លំដោយ។ នីតាស្ថិតក្នុងសម្លៀកបំពាក់កាន់ទុក្ខ កំពុងអង្គុយក្បែរក្តារមឈូសម្តាយ ដុតក្រដាសសែនម្តងមួយសន្លឹក និងយកពេលខ្លះមកគោរព

ភ្ញៀវដែលមកចូលរួមពិធីបុណ្យ។ ប្ដីរបស់នាងនៅឈរចាំទទួលភ្ញៀវនៅខាងមុខផ្លូវ និងមើលការខុសត្រូវរឿងឡានម៉ូតូ កុំឲ្យស្ទះការធ្វើដំណើររបស់អ្នកភូមិ។

លក្ខិណា និងដានីដែលជាមិត្តរួមការងារ បានមកកេះខ្នងនីតា ហើយដានីក៏និយាយថា "នីតា! ទៅរកអីញ៉ាំសិនទៅ ចាំពួកខ្ញុំជួយដុតក្រដាសជំនួស។" ដានីឈរកាន់ដបទឹកសុទ្ធដែលផឹកអស់កន្លះដប ធ្វើមុខមិនសូវសប្បាយចិត្ត ព្រោះឃើញមិត្តភក្ដិខ្លួនស្ថិតក្នុងសភាពបែបនេះ។

នីតាមិននិយាយអ្វី  គ្រាន់តែគ្រវីក្បាល បញ្ជាក់ថា នាងមិនចង់ដើរចេញម្ដាយរបស់នាងទេនៅពេលនេះ។ មិត្តភក្ដិទាំងពីរងាកមើលមុខគ្នា ហើយដានីក៏រកនឹកហេតុផលថា "កុំអ៊ីចឹងអី អត់ញ៉ាំអី បើដួលម្នាក់ទៀត បានអ្នកណាជួយប្ដីឯង?" នីតាងាកមើលទៅប្ដីនាងដែលកំពុងរត់ទៅរត់មក នៅមុខរោងបុណ្យ ទើបនាងក៏ព្រមងើបឡើង ដើម្បីឲ្យដានី និងលក្ខិណាចូលជំនួស។

"ដុតមួយៗ កុំប្រញាប់ពេក ហើយបើទៀននេះឆេះអស់ លូកយកទៀនក្រោមតុមកប្រើទៅ។" នីតាផ្ដាំផ្ញើរួច ក៏ដើរចេញដើម្បីរកបាយទ្រាប់ពោះបន្តិច ព្រោះនាងអត់មានអីចូលពោះតាំងពីយប់មក។ នីតាបម្រុងដើរចូលទៅក្នុងផ្ទះ តែនាងបានក្រឡេកភ្នែកទៅឃើញ ម៉ូតូមួយគ្រឿងដែលមានមនុស្សប្រុសពីរនាក់ដែលនាងខានឃើញមុខប៉ុន្មានខែមកហើយ។ មករា និងទំនោរទើបនឹងចតម៉ូតូរួច ដើរចូលមកក្នុងរោងបុណ្យ។

មករា កាន់ស្រោមសំបុត្រសមួយពីតុបុណ្យខាងមុខរោង ដើម្បីទុកដាក់លុយ ចូលជាបច្ច័យដល់គ្រួសារសព។ មករា ឃើញនីតាពីចម្ងាយ ក៏ដកដង្ហើមធំ។ គេក្រឡេកមើលទៅទំនោរ ឃើញមិត្តរបស់គេធ្វើដូចជាធម្មតា។ គេឆ្ងល់បន្តិច តែក៏គិតក្នុងចិត្តថា "អានេះ ប្រហែលជាធ្វើឫក កុំឲ្យនីតាដឹងថាវានៅស្រលាញ់គេប៉ុណ្ណោះ។"

គ្រាន់តែឃើញទំនោរ ទឹកភ្នែករបស់នីតាក៏ហូរចេញមកភ្លាម។ អារម្មណ៍របស់នាងពេលនេះ ទាញយកគ្រប់រឿងទាំងអស់មកវាយប្រហារទឹកចិត្តខ្លួនឯង។ ទាំងរឿងម្ដាយស្លាប់ និងរឿងដែលនាងធ្លាប់ធ្វើដាក់ទំនោរ។ ទំនោរញញឹមបន្តិចពេលឃើញមុខរបស់នីតា ហើយបែរមុខទៅរកសពអ៊ំស្រី។ ទំនោរលុតជង្គង់ និងយកធូបដុតដើម្បីជាការគោរពដល់អ៊ំស្រី។ នីតាសម្លឹងមុខទំនោរជាប់រហូត តែមិនមាននិយាយអ្វីទាំងអស់។ មករាក៏ចូលក្រោយទំនោរ ហើយឱនសំពះសពបន្តិច ក្រោយពេលដុតធូបរួច។

"អ៊ំអើយអ៊ំ ខ្ញុំសូមខមាលទោសផង បើសិនជាបានធ្វើអ្វីខុសឆ្គងកន្លងមក។ បើសិនជាមានជិតក្រោយ សូមឲ្យអ៊ំជៀសផុតពីរឿងមិនល្អបែបនេះ។" មករា ខ្សិបៗម្នាក់ឯង ដោយយកធូបបាំងមាត់ជីបអូចៗ។

មករា ដានី លក្ខិណា ទំនោរ និងនីតា ស្គាល់គ្នាជិតជិតណាស់ ជាពិសេសពេលដែលទំនោរ និងនីតា នៅជាគូសង្សារ។ ពួកគេខាននិយាយគ្នា ក្រោយពេលនីតា និងទំនោរបែកផ្លូវគ្នា ព្រោះម្ខាងជាមិត្តខាងប្រុស និងម្ខាងទៀតជាមិត្តខាងស្រី។ មករា ញញឹមដាក់ដានី និងលក្ខិណា ហើយនិយាយខ្សិបៗថា "បើកុំតែឃើញពីនាក់ឯងផុសរូបកាលពីយប់ កុំអីខ្ញុំក៏មិនដឹងដែរ។ ខ្ញុំខានជិះមកផ្លូវនេះយូរហើយ។" លក្ខិណានិយាយថា "ខ្ញុំផុស ព្រោះចង់ឲ្យមករាឯងយកទៅប្រាប់ទំនោរហ្នឹង។ ខ្ញុំចង់ឲ្យទំនោរមកលាអ៊ំស្រី"។

ទំនោរក្រោកឡើងមក លាត់ដៃអាវត្រៀមខ្លួនដើម្បីជួយធ្វើការខ្លះ។ ទំនោរងាកមើលមុខនីតាចំ នាងក៏យំ ហើយរត់មកឱបទំនោរតែម្តង។ គេថាមនុស្សយើងនឹងបញ្ចេញភាពទន់ជ្រាយ ពេលនៅចំពោះមុខមនុស្សដែលស្និទ្ធស្នាលបំផុត។ ទោះបីជានីតាស្រលាញ់អ្នកផ្សេងមែន តែទំនោរនៅតែជាអ្នកដែលស្និទ្ធស្នាលនឹងនាងជាងគេក្នុងពេលនេះ។ ទំនោរមិនចម្លែកចិត្តទេ ពេលនីតាធ្វើបែបនេះ ព្រោះវាមិនមែនជាលើកទីមួយដែលនាងយំឱបគេ។ ក្នុងចិត្តរបស់ទំនោរពេលនេះ ហាក់ដូចជាអានិតនីតា ហើយក៏ដូចជាស្តាយក្រោយនូវអ្វីដែលគេបានធ្វើ ប៉ុន្តែក៏មានកូនចិត្តមួយទៀត ដែលប្រាប់គេឲ្យពេញចិត្ត ព្រោះនេះជាអ្វីដែលគេចង់បាន។

មិត្តភក្តិបីនាក់ មើលមុខគ្នា ព្រោះមិនដឹងថាត្រូវធ្វើអ្វី។ ពួកគេដឹងថា នីតាឈប់ស្រលាញ់ទំនោរយូរហើយ តែហេតុអ្វីបានជាឈរឱបគ្នា? ទំនោរយកដៃគោះស្មានីតាតិចៗ ដើម្បីបញ្ជាក់ថា គេក៏យល់ពីអារម្មណ៍នីតាដែរ។ "ប្រយ័ត្នប្តី ប្រច័ណ្ឌ ទើបនឹងរៀបការផង" ទំនោរខ្សឹបប្រាប់នីតា។ នីតាក៏ដកមុខឡើង ហើយជូតទឹកភ្នែកចេញ ហាក់ដូចជាអៀនខ្លួនឯងបន្តិច។ នីតារៀបការ ដោយមិនមានផ្តល់ដំណឹងអ្វីដល់ទំនោរទេ។ បើនិយាយឲ្យចំ គឺនាងប្រឹងលាក់រឿងនេះតែម្តង។ បើកុំតែបានមិត្តភក្តិដែលជាភ្នាក់ងារទាន់ហេតុការណ៍ពីរនាក់របស់នាង ទំនោរក៏មិនបានដឹងដែរ។ នាងក៏ធ្វើជានិយាយថា "ទំនោររកអីញ៉ាំសិនទៅ ខ្ញុំទៅក្នុងសិនហើយ"។

ពាក្យបងអូន ប្តូរមកជាការហៅឈ្មោះ។ ទម្លាប់នៃការហៅគ្នា ធ្វើឲ្យអ្នកទាំងពីរមិនទម្លាប់មាត់នៅពេលត្រូវប្រើឈ្មោះឡើងវិញ។ ទំនោរ និងមករា ក៏ដើរទៅរកតុអង្គុយ ហើយជជែកគ្នាពីការស្លាប់របស់អ៊ំស្រី។

នៅពេលដែលគូសង្សារចាស់កំពុងឈរឱបគ្នា ចេស្តាបានឃើញរូបភាពនេះ។ គេឆ្ងល់ណាស់ តើប្រុសនោះជាអ្នកណា ព្រោះដូចជាមិនបានឃើញមុខថ្ងៃរៀបការ ហើយនីតាក៏មិនដែលនិយាយអ្វីប្រាប់ទៀត។ ចេស្តាគិតថា ចាំបុណ្យចប់ ចាំសួរល្អជាង។ ចេស្តា អាចទាយដឹងខ្លះថា ប្រុសម្នាក់នេះ អាចនឹងមានភាពជិតដិតជាមួយនីតា ព្រោះនីតាមិនងាយយំនៅនឹងមុខអ្នកដទៃទេ។ នាងតែងតែប្រឹងធ្វើខ្លួនជាមនុស្សដែលរឹងប៉ឹងជានិច្ច។

ចេស្តាគ្រវីក្បាល ហើយគិតក្នុងចិត្តថា "មិនបាច់ចប់បុណ្យទេ ចាំហៅលក្ខិណា និងដានីមកសួរក៏បានដែរ។" ដានី និងលក្ខិណា ជាថ្នាក់ក្រោមរបស់ចេស្តា ហើយទូទៅតែងត្រូវចេស្តាសួរចម្លើយ ពីរឿងនីតា ជានិច្ច។

ទំនោរសម្លឹងមើលទៅរូបថតរបស់អ៊ំស្រីដែលបញ្ឈរនៅមុខក្តារមឈូស។ គេមិនដឹងថា តើព្រលឹងរបស់អ៊ំស្រី គិតយ៉ាងណាចំពោះគេទេនៅពេលនេះ។ គេក៏មិនដឹងថា តើគេអាចរលាក់អ្វីដែលគេធ្វើបានយូរប៉ុណ្ណាដែរ។ គេគិតក្នុងចិត្តថា "ខ្ញុំធ្វើខុសហើយអ៊ំ តែខ្ញុំក៏ធ្វើត្រូវដែរលើកនេះ"។

# ភាគទី៧

ចេស្តា មើលការខុសត្រូវនៅខាងក្រោបណ្ដើរ លួចសម្លឹងមើលដានី និងលក្ខិណាបណ្ដើរ។ គេចាំឲ្យមានអ្នកណាចូលអង្គុយជុតក្រដាសជំនួស គេនឹងសួរពីរនាក់នោះឲ្យអស់សង្ស័យ។ ចេស្តា ក្រឡេកមើលទៅតុ ដែលទំនោរ និងមករាកំពុងអង្គុយ។ គេមើលមុខទំនោរ ហើយគិតក្នុងចិត្ត ម្នាក់នេះមុខមាត់ស្លូតបូត គួរតែមិនមានចិត្តមិនល្អមកលើប្រពន្ធខ្លួនទេ។ ទំនោរ ចោលភ្នែកម្ដងៗទៅកាន់ចេស្តា ឃើញថាចេស្តាកំពុងតែសម្លឹងមកតុខ្លួន គេក៏ធ្វើជាមិនដឹងខ្លួន ហើយធ្វើទឹកមុខធម្មតា។

ទំនោរនិយាយទៅកាន់មករា "នីតា ជួបរឿងល្អផង រឿងអាក្រក់ផងតំណាលគ្នា ប្រហែលជាមិនស្រួលធ្វើចិត្តទេ"។

មករាទម្លាក់ស្លាបព្រាបបរចុះដើម្បីតប "វាដឹងតែអ៊ីចឹងហើយ នីតានៅតែពីរនាក់ម៉ែកូនយូរមកហើយ។ ឥលូវ ស្រាប់តែលែងមានម៉ែហៅ ហ៊ើយ... មិនគួរមានរឿងអ៊ីចឹងសោះ"។ ដោយឃើញទំនោរនៅស្ងៀម មករាក៏បន្តទៀត "ខ្ញុំដូចមិនយល់សោះថា តើអ៊ំស្រីទៅមានរឿងជាមួយអ្នកណា បានជាគេមកសម្លាប់គាត់ដល់ផ្ទះបែបនេះ?"

"យើងមិនដឹងរឿងរបស់គាត់ទេ ហើយបើតាមខ្ញុំគិត នីតាក៏មិនដឹងដែរ" ទំនោរឆ្លើយដើម្បីបញ្ចប់សំណួរ។

"តោះ ឆ្អែតហើយ ទៅជួយអង្គុយជុតក្រដាសមួយភ្លែត មុនទៅវិញ" មករាកេះទំនោរ។ ទំនោរមិនប្រកែកអ្វីទេ ក៏ងើបចេញពីតុ ហើយទៅអង្គុយមុខសព។ ដានី និងលក្ខិណាក៏ងើបចេញ។ ទំនោរហាក់ដូចរអៀសខ្លួននៅពេលសម្លឹងមើលរូបថតអ៊ំស្រី ប៉ុន្តែគេអាចធ្វើខ្លួនធម្មតាបាន ដើម្បីកុំឲ្យមានការសង្ស័យ។

ចេស្តាឃើញដានី និងលក្ខិណាដើរចេញមក គេក៏ស្រែកហៅដានី។ ដានីលឺគេហៅឈ្មោះក៏ងាកទៅមើល ឃើញចេស្តាកំពុងតែបក់ដៃហៅដូចជាប្រញាប់រឿងអ្វីមួយ។ ដានីក៏ដើរទៅ ទុកឲ្យលក្ខិណានៅឈរម្នាក់ឯង។

"មានការអីបងចេស្តា?"

"ដើរទៅក្រៅជាមួយបងបន្តិច" ចេស្តារកមើលកន្លែងស្ងាត់មនុស្ស ដើម្បីងាយសួរ។ ដានីឆ្ងល់ក្នុងចិត្ត តែមិនសួរអ្វីបន្ថែម ក៏ដើរតាមចេស្តាទៅខាងមុខផ្លូវ។

រកឃើញកន្លែងល្អហើយ ចេស្តាក៏ឈប់ ហើយនិយាយថា "ប្រាប់បងតាមត្រង់ កុំលាក់ ម្នាក់ប្រុសដែលនីតាឈរឱបមុននោះ ត្រូវជាអីនឹងនីតា?" ចេស្តាបើកភ្នែកធំមើលដានី ហាក់ដូចជាបញ្ជានាងឲ្យឆ្លើយតាមត្រង់។

"ខ្ញុំថា បងចាំសួរនីតាខ្លួនឯងទៅ ល្អជាង ខ្ញុំមិនចង់ពាក់ព័ន្ធទេ" ដានីព្យាយាមឆ្លើយយករួចខ្លួន ប៉ុន្តែចេស្តាមិនឈប់។

"នីតា កំពុងពិបាកចិត្ត ឲ្យបងទៅសួររឿងហ្នឹងម៉េចកើត ហើយកុំប្រាប់ថាឲ្យបងចាំ ព្រោះបងចង់ដឹងចម្លើយឥលូវនេះ"

"ខ្ញុំប្រាប់បានតែអ្វីដែលខ្ញុំដឹងទេ ហើយបើនីតាសួរ កុំភ្លេចប្រាប់ថា បងបង្ខំឲ្យខ្ញុំនិយាយ មិនមែនខ្ញុំចង់និយាយទេ" ដានីដាក់លក្ខខណ្ឌមុននឹងឆ្លើយសំនួរដែលពាក់ព័ន្ធនឹងមិត្តសម្លាញ់របស់នាង។

"ដឹងហើយ និយាយមក បងចាំស្តាប់"

"ម្នាក់ប្រុសនោះឈ្មោះទំនោរ ហើយម្នាក់ដែលមកជាមួយគេឈ្មោះមករា ជាមិត្តភក្តិរបស់ខ្ញុំ។ មុនពេលនីតាចូលធ្វើការក្នុងក្រុមហ៊ុនជាមួយបងចេស្តាឯង នីតាធ្លាប់ជាសង្សាររបស់ទំនោរ។ ពួកគេស្រលាញ់គ្នាប្រហែលជាពីរឆ្នាំ ឬលើសពីហ្នឹង ខ្ញុំមិនសូវច្បាស់ទេ" នីតាផ្អាកបន្តិច ដើម្បីមើលទឹកមុខរបស់ចេស្តា ប៉ុន្តែដោយឃើញថាមិនអី នាងក៏បន្តទៀត "ក្រោយពេលស្គាល់បងឯង នីតាក៏លែងស្រលាញ់ទំនោរ។ នីតាសុំបែកគ្នាប្រហែលជាប៉ុន្មានខែមុនពេលរៀបការ។"

"នីតាសុំគេបែក?"

"បើតាមខ្ញុំដឹង នីតាធ្វើរឿងច្រើនណាស់ ឲ្យទំនោរសុំបែកមុន ព្រោះនីតាមិនចង់ឲ្យទំនោរពិបាកចិត្ត តែទោះធ្វើយ៉ាងណាក៏ទំនោរមិននិយាយអ្វី។ ដល់ចុងក្រោយ នីតាក៏សុំបែកទៅ។ នីតាមិនបានប្រាប់គេថា បែកគ្នាដោយសារអ្វីទេ។ ទំនោរធ្លាប់សួរខ្ញុំដែរ តែខ្ញុំប្រាប់ថាមិនដឹង។"

"គេបែកគ្នាដោយសារបង?"

ដានីមិនឆ្លើយសំនួរនេះ តែនិយាយរឿងផ្សេង "បងចេស្តាឯងនៅចាំពេលទើបស្គាល់គ្នាជាមួយនីតាដែរ ទេ។ ពេលខ្លះ នីតាហុចទូរស័ព្ទឲ្យខ្ញុំលើកជំនួសនោះ?"

ចេស្តាគិតមួយភ្លែតរួចតប "ទំនោរតេរមក ហើយនីតាមិនចង់និយាយជាមួយ ត្រូវអត់?"

"ហ្នឹងហើយ ខ្ញុំត្រូវរកលេសប្រាប់ទំនោរថានីតារវល់ការងាររហូត។ ខ្ញុំពិបាកណាស់ ខ្ញុំក៏ស្គាល់ទំនោរដែរ ហើយខ្ញុំត្រូវកុហកគេបែបនេះរហូតដល់នីតាសុំគេបែកគ្នា។" ដានីនិយាយដោយចងចិញ្ចើមក្រោយគិត ឡើងវិញពីអ្វីដែលនាងបានធ្វើ។

"ខ្ញុំមិនដឹងទេ ទោះបីខ្ញុំជាមិត្តភក្តិនីតាមែន ក៏ខ្ញុំគិតថា នីតាធ្វើខុសដាក់ទំនោរដែរ។ បងឯងមិនបាន ឃើញពេលនីតាគេចមុខពីគេទេ។ ទំនោរមកឈរចាំនីតារាប់ម៉ោងនៅមុខផ្ទះ តែនីតាមិនចេញពីផ្ទះ ពេញមួយថ្ងៃ ដល់ពេលចេញមក ក៏ជិះម៉ូតូទៅណាបាត់ទៀត។ សូម្បីតែមុខ ក៏នីតាមិនមើលផង"

ចេស្តាបម្រុងនឹងសួរបន្តទៀត តែដានីនិយាយស្កាត់មុន "ខ្ញុំប្រាប់បានតែប៉ុណ្ណឹងទេ បើបងចង់ដឹងអ្វី ទៀត ចាំសួរប្រពន្ធបងខ្លួនឯងទៅ"។ ដានីដើរបានប៉ុន្មានជំហាន ក៏ងាកក្រោយមកនិយាយថា "ទំនោរ ជាមនុស្សល្អ ស្រួលនិយាយគ្នាទេ បើបងឯងមិនប្រកាន់ ទៅសួរគេក៏បានដែរ" ។

ចេស្តាឈរស្ងៀមដើម្បីគិតពីអ្វីដែលដានីទើបនឹងប្រាប់គេ។ នីតាដែលគេស្គាល់ ជាមនុស្សដែលចេះ និយាយហេតុផល និងគោរពអ្នកដទៃ ប៉ុន្តែហេតុអ្វីបានជានាងធ្វើបែបនេះដាក់សង្សារចាស់របស់នាង កើត? ចេស្តា គិតថាខ្លួនឯងស្គាល់ពីនីតាហើយ ទើបសម្រេចចិត្តថារៀបការជាមួយគ្នា ប៉ុន្តែពេលនេះ គេប្រហែលជាត្រូវគិតឡើងវិញ។ បើសិនជាអ្វីដែលដានីប្រាប់គេជាការពិត ហើយទំនោរជាមនុស្សល្អ តើនីតាជាមនុស្សបែបណា? ចេស្តាគ្រវីក្បាល ក្រោយពេលការគិតរបស់គេក្លាយជាការសង្ស័យប្រពន្ធ របស់ខ្លួនឯង។

ចេស្តាដើរត្រលប់ទៅក្នុងវិញ ដោយក្នុងចិត្តកំពុងច្របូកច្របល់។ គេសម្រេចថាមិនឲ្យរឿងដែលកើត ឡើងហើយ បំផ្លាញទំនាក់ទំនងរវាងគេ និងនីតាទេ។ គេមានគ្រួសារហើយនៅពេលនេះ ហើយអ្វីដែល ចាំបាច់បំផុតសម្រាប់គ្រួសារ គឺការទុកចិត្តគ្នា។ បើនីតាជ្រើសរើសរៀបការជាមួយគេហើយ បានន័យ ថា នាងទុកចិត្តគេហើយ។ ចេស្តាញញឹមនៅពេលគិតដល់ត្រង់នេះ។

មករា និងទំនោរដើរចេញពីកម្មវិធីបុណ្យ ស្របពេលដែលចេស្តាដើរចូលទៅ។ ចេស្តាគិតថា ទំនោរមិនដឹងថាគេជាប្តីរបស់នីតា ហេតុនេះក៏ឈរញញឹមក្នុងនាមជាម្ចាស់បុណ្យ។ "អរគុណដែលមកចូលរួមបុណ្យ" ចេស្តានិយាយដោយសម្តីទន់ភ្លន់ និងឱនក្បាលគោរពបន្តិច។

មករា លើកដៃជម្រាបលា ដោយមិននិយាយអ្វី។ ទំនោរគ្រាន់តែញញឹមតបជាការសមគួរប៉ុណ្ណោះ។ ពួកគេក៏ឡើងជិះម៉ូតូចេញទៅ។ ទំនោរមិនមាត់អ្វីទាំងអស់នៅលើម៉ូតូ ព្រោះតែរូបភាពដែលចេស្តាឈរញញឹមដាក់គេ បែរជាធ្វើឲ្យគេកាន់តែទ្រាំមិនបាន។

# ភាគទី៨

កន្លងផុតទៅមួយអាទិត្យ...

ប៉ូលីសនៅតែរកមិនឃើញជនសង្ស័យដែលសម្លាប់ម្ដាយនីតា។ នីតា នៅតែសំកុកមើលរូបថតម្ដាយក្រោយពេលត្រលប់មកធ្វើការ។ ការចាកចេញដោយមិនបានព្រៀងទុកធ្វើឲ្យនីតាមិនអស់ចិត្ត ប៉ុន្តែនាងមិនដឹងនិយាយប្រាប់អ្នកណាឲ្យយល់ពីទុក្ខលំបាកក្នុងចិត្ត។ សូម្បីតែប្ដីរបស់នាង ក៏មិនអាចជួយអ្វីបានក្រៅពីលួចមើលប្រពន្ធ ហើយដកដង្ហើមធំដែរ។ រាល់ពេលដែលចេស្ដាព្យាយាមរកវិធីឲ្យនីតានិយាយពីអារម្មណ៍ខាងក្នុងប្រាប់គេ នីតានិយាយបានត្រឹមតែ "អូននឹងម៉ាក់ណាស់បង"។

ឪពុកម្ដាយរបស់ចេស្ដា ក៏ឧស្សាហ៍ចូលមកលេងកូនទាំងពីរ ដើម្បីកុំឲ្យស្ងាត់ពេក។ ពួកគាត់គិតចង់ជួយ ទម្រាំតែនីតាអាចកាត់ចិត្ត ហើយមានសភាពធម្មតាវិញ។ ពួកគាត់ព្យាយាមយករឿងសប្បាយៗពីខាងក្រៅ មកផ្លាស់ប្ដូរបរិយាកាសក្នុងផ្ទះ។ នីតា ដឹងពីបំណងល្អរបស់ពួកគាត់ ហេតុនេះក៏ចេះតែសម្របខ្លួនតាម។

ទំនោរ តាមដានពត៌មានជាប់ពេញមួយអាទិត្យ ព្រោះចង់ដឹងថាតើប៉ូលីសមានតម្រុយអ្វីដែលអាចនាំមកដល់គេឬអត់។ ក្រោយពេលស្ងាត់ជ្រាប គេហាក់ដូចជាទុកចិត្តបន្តិចថា គេមិនបានបន្សល់ស្លាកស្នាមអ្វីទេ។ ទំនោរត្រូវត្រលប់ទៅធ្វើការវិញ ក្រោយពេលកុហកប្រធានរបស់គេថា ត្រូវទៅស្រុកមើលម្ដាយ។

ទំនោរ ធ្វើការផ្នែកគ្រប់គ្រងទិន្នន័យក្នុងក្រុមហ៊ុន។ កិច្ចការដែលគេធ្វើប្រចាំថ្ងៃ គឺដដែលៗ។ ក្នុងមួយខែ គេត្រូវធ្វើការដាច់យប់ម្ដងប៉ុណ្ណោះ ដើម្បី back up ទិន្នន័យក្រុមហ៊ុន។ ទំនោរ មិនសូវពេញចិត្តនឹងការងាររបស់គេប៉ុន្មានទេ ជាពិសេសក្រោយពេលដែលនីតាឈប់ទៅធ្វើការនៅក្រុមហ៊ុនផ្សេងមក។ កាលពីមុន ទំនោរមកធ្វើការដើម្បីបានជួបជាមួយនីតា ឥលូវគេមកធ្វើការព្រោះមិនដឹងថាត្រូវធ្វើអ្វី។ គោលបំណងរបស់គេ គឺមានលុយចាយគ្រប់គ្រាន់ និងមិនឈឺផ្តេសផ្ដាសប៉ុណ្ណោះ។

ព្រឹកនេះ ទំនោរត្រូវចូលរួមប្រជុំជាមួយប្រធានផ្នែកផ្សេងទៀត។ គេស្អប់ការប្រជុំខ្លាំងណាស់ ប៉ុន្តែគ្មានជម្រើសទេ ព្រោះនេះជាបញ្ហាថ្នាក់លើ។ នៅក្នុងការប្រជុំ ទំនោរបណ្ដែតអារម្មណ៍ថា បើសិនជាពេលនេះគេទៅធ្វើអ្វីផ្សេងដែលរំភើប និងប្លែកជាងនេះ មិនដឹងជាល្អយ៉ាងណាទេ។ នឹកដល់រឿងរំភើប ទំនោរនឹកដល់ផែនការរបស់គេ។ គេក្ដាប់ដៃយ៉ាងណែននៅក្រោមតុ ហើយបិទភ្នែកស្រមៃដល់ពេលដែលគេធ្វើតាមផែនការបានសម្រេចទាំងអស់។

នៅក្រុមហ៊ុនដែលនីតាធ្វើការ

ដល់ម៉ោងបាយហើយ ចេស្ដាសួរប្រពន្ធខ្លួន ថាចង់ញ៉ាំអី ចាំគេទៅទិញឲ្យ ព្រោះមិនចង់ឲ្យនាងចេញទៅក្រៅ។ ម្យ៉ាងទៀត ចេស្ដាចង់យកម៉ោងបាយដែលបុគ្គលិកផ្សេងទៅក្រៅអស់ សួរនីតាពីរឿងទំនោរ។ គេមិនទាន់អស់ចិត្ត ហើយចង់ឲ្យនីតាប្រាប់គេដោយផ្ទាល់។

"ចាំនៅហ្នឹងហើយ បងទៅតែមួយភ្លែតទេ" ចេស្ដាប្រាប់នីតាបណ្ដើរ លូកយកកាបូបលុយពីក្នុងកាតាបមកបណ្ដើរ។ ចេស្ដាដើរចេញទៅ ទុកនីតាឲ្យនៅប្រឹងធ្វើការបន្ទប់ទុក្ខម្នាក់ឯង។

ដានីដើរកាត់បន្ទប់ឃើញនីតានៅអង្គុយម្នាក់ឯង ក៏អើតមកសួរ "នីតា! អត់ទៅបាយទេ?"

"បងចេស្ដាទៅទិញបាយមកហើយ ថ្ងៃហ្នឹងខ្ជិលទៅក្រៅណាស់"

"អឺ អ៊ីចឹងខ្ញុំទៅញ៉ាំហើយ ព្រោះគ្មានប្ដីឯណាទិញបាយឲ្យដូចឯងទេ" ដានីនិយាយលេងសើចបន្តិច រួចក៏ដើរចេញទៅ។

មួយសន្ទុះក្រោយមក ចេស្ដាត្រលប់មកវិញជាមួយបាយឆាពីរប្រអប់។ ចេស្ដារៀបចំឥវ៉ាន់លើតុឲ្យស្រឡះបន្តិចដើម្បីដាក់ប្រអប់បាយ។ ពេលកំពុងញ៉ាំ នីតាឃើញចេស្ដាចេះតែសម្លឹងមើលមុខខ្លួនរហូត ក៏សួរថា "មានរឿងអីចង់និយាយមែន បង?"។

"បងមានរឿងមួយចង់សួរ តែបើសិនអូនឯងមិនទាន់ចង់និយាយ មិនបាច់និយាយក៏បានដែរ" ចេស្ដាហាក់ដូចស្ទាក់ស្ទើរបន្តិច ព្រោះមិនដឹងថាគួរសួរឬអត់។

"សួរមក មិនអីទេ"

"បងចង់ដឹងពីរឿងទំនោរ" ចេស្តានិយាយដោយម៉ឺងម៉ាត់។

នីតា ហាក់ដូចជាគេចាក់ឲ្យភ្ញាក់ ព្រោះគេមិនដែលនិយាយពីរឿងនេះជាមួយចេស្តាទាល់តែសោះ។ នាងក៏នឹកឃើញដល់ថ្ងៃបុណ្យសព ដែលនាងឈរឱបទំនោរមួយភ្លែតនោះ ហើយប្រហែលជាប្តីរបស់នាងបានឃើញហើយ។ នីតា ចង់រកលេសមិននិយាយ តែគិតថាមិនសម ក៏សម្រេចចិត្តប្រាប់គ្រប់យ៉ាងឲ្យចេស្តាដឹង។

"ទំនោរ ត្រូវជាសង្សារចាស់អូន។ យើងស្រលាញ់គ្នាប្រហែលជា២ឆ្នាំ ហើយក្រោយមកអូនក៏បែកគ្នាជាមួយគេ។"

"អូនបែកគ្នាដោយសារអី?"

"ដោយសារអូនស្គាល់បងឯង" នីតានិយាយត្រង់ៗ ព្រោះនាងគិតថា នាងធ្លាប់កុហកទំនោរម្តងហើយ ហេតុនេះនាងមិនចង់កុហកអ្នកដែលនាងស្រលាញ់ទៀតទេ។ "អូនធ្វើបាបទំនោរច្រើនណាស់បង មុនពេលបែកគ្នា។ អូនស្បថ អូនមិនដែលចង់ធ្វើឲ្យអ្នកណាពិបាកចិត្តដោយសារអូនទេ តែពេលហ្នឹង អូនមិនដឹងធ្វើយ៉ាងម៉េចទើបគេព្រមបែក។ ពេលឃើញមុខទំនោរ អូនខ្មាសខ្លួនឯងណាស់។"

នីតាសម្លឹងមើលមុខចេស្តា ប៉ុន្តែមិនឃើញមានអ្វីប្លែក នាងក៏ចូល "បងដឹងរឿងហ្នឹងអស់ហើយ ត្រូវអត់?"

"បងហៅជានីសួរ តែជានីប្រាប់បងមិនទាន់អស់ទេ។ អូននៅស្រលាញ់ទំនោរទៀតអត់?"

"អត់ទេ អត់មានទេ។ ពេលអូនស្គាល់បងឯងភ្លាម អូនចាប់ផ្តើមស្រលាញ់បងឯងបាត់ហើយ។" នីតានិយាយថយសម្លេងបន្តិច "បងគិតថាអូនជាស្រីមិនល្អហើយ ត្រូវអត់?"

ចេស្តាគ្រវីក្បាល ហើយនិយាយយ៉ាងស្រួលជាមួយនីតា "អត់ទេ! អ្នកណាក៏ធ្លាប់ធ្វើខុសដែរអូន។ អូនក៏ដឹងខ្លួនថាខុសដែរ។ បងពិបាកនិយាយណាស់ ព្រោះអូនឈប់ស្រលាញ់គេ ហើយមកស្រលាញ់បង។ បងក៏ចង់ឲ្យអូនស្រលាញ់បងដែរ។" ចេស្តាយកដៃអង្អែលក្បាលប្រពន្ធ ដើម្បីឲ្យនាងទុកចិត្ត។

"ក្រៅពីអារឿងស្រលាញ់គ្នាហ្នឹង អូនស្និទ្ធជាមួយទំនោរអត់?"

នីតាគិតមួយសន្ទុះ ហើយនិយាយ "បើគិតពីស្និទ្ធ អាចថាស្និទ្ធជាងដានីជាមួយលក្ខិណាទៀត។ មុនពេលស្រលាញ់គ្នា ទំនោរក៏ជាមិត្តភក្តិអូនដែរ។ ពីមុន មានរឿងពិបាកចិត្តអី អូនទៅនិយាយជាមួយទំនោរហើយ។"

"ចុះឥលូវ? បងស្គាល់អូនមិនសូវយូរទេ អ៊ីចឹងរឿងខ្លះ បងក៏មិនសូវដឹងពីអូនច្បាស់ដែរ។ បើអូនទៅនិយាយជាមួយទំនោរវិញ អាចជួយឲ្យអូនធូរចិត្តដូចមុនដែរទេ?"

នីតាទម្លាក់ទឹកមុខហើយនិយាយ "ទោះចង់និយាយ ក៏គេលែងនិយាយជាមួយអូនដែរ។ អូនដឹងថាគេខឹងអូន។ គេមិនខាតពេលមកស្តាប់អូននិយាយរឿងអត់បានការទៀតទេ។"

"អូនមានសាកសូមទោសគេហើយនៅ? បើគេចេះនិយាយហេតុផល គេអាចនឹងយល់បាន។ ថាមិនត្រូវអូនអាចបានមិត្តភក្តិមួយនេះមកវិញផង។" ចេស្តាលើកជាយោបល់។ "បើគេនៅខឹងអូន គេមិនមកបុណ្យម៉ាក់ទេ"។

"ទំនោរស្គាល់ម៉ាក់យូរហើយបង គេមក ក៏គ្មានអីចម្លែកដែរ" នីតាប្រកែក។

"បងគ្រាន់តែឲ្យជាយោបល់ទេ តែបងគិតថា បើអូនសូមទោសគេ អូនក៏បានធូរចិត្តខ្លួនឯងដែរ។ បងគិតថា ទំនោរមិនចិត្តដាច់ទេ។ អូនគិតមើលខ្លួនឯងទៅ។" ចេស្តានិយាយរួច ក៏ឈ្ងោកមុខញ៉ាំបាយបន្តទៀត។

នីតា មិនធ្លាប់គិតពីការសូមទោសទំនោរពីមុនមកទេ។ នាងដឹងថានាងធ្វើខុស តែមិនគិតថាទទួលស្គាល់កំហុសខ្លួនឯងនៅមុខទំនោរ។ ចេស្តា មានអាយុច្រើនជាង ហេតុនេះគេចង់បង្រៀនប្រពន្ធរបស់គេឲ្យធ្វើខ្លួនជាមនុស្សចាស់ទុំម្នាក់។ ចេស្តា គិតថា ទំនោរអាចជួយសម្រាលទម្ងន់នៃការបាត់បង់ម្តាយរបស់នីតាបាន។ គេក៏គិតដែរថា ការស្លាប់របស់ម្តាយនីតា អាចបង្ខំឲ្យទំនោរទទួលយកការសូមទោសរបស់ប្រពន្ធគេ។

ចេស្តា រអៀសខ្លួន ទោះបីគេមិនមែនជាអ្នកខុសដាក់ទំនោរក៏ដោយ។ គេមិនទាំងដឹងថា ទំនោរជាអ្នកណាផងពីមុន។ គេក៏មិនចង់ឲ្យអ្នកណាម្នាក់ស្អប់ប្រពន្ធគេដែរ។